# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤៧.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើត អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**ប្រការ១ :** តែងតាំងមុខងារ នាយទាហាននៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖

១-វរសេនីយ៍ទោ **សុខ រ៉ូមី** អត្តលេខ ១៣៨៣៨២ ជា ជំនួយការ រដ្ឋបាលនិងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធា អមស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ជំនួស វរសេនីយ៍ទោ ម៉ៅ សុវ័ក្ត្រ ដែលត្រូវទទួលភារកិច្ចថ្មី

២-វរសេនីយ៍ទោ **ម៉ៅ សុវ័ក្ត្រ** អត្តលេខ ០៧៣៩៤៣ ជា ជំនួយការ រដ្ឋបាល និងបច្ចេកទេស ការិយាល័យអនុព័ន្ធយោធា អមស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងកង់បេរ៉ា ប្រទេសអូស្ត្រាលី

www.pheakdeylaw.com

៣-វរសេនីយ៍ត្រី **ម៉ន ចំរ៉ុង** អត្តលេខ ១៦៣៧៥៩ ជា ជំនួយការ រដ្ឋបាល និងបច្ចេកទេស ការិយាល័យ អនុព័ន្ធយោធា អមស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េខាងត្បូង ជំនួស វរសេនីយ៍ឯក ថន ដារ៉ា ដែលត្រូវទទួលភារកិច្ចថ្មី

**ប្រការ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ អង្គារ ៩ រោច ខែ ស្រាពណ៍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com